**ទីក្រុងឡុងប៊ិច**
**ការវិភាគមិនលំអៀងរបស់មេធាវីក្រុង ចំពោះវិធានការ BB**

**វិសោធនកម្មធម្មនុញ្ញដើម្បីច្របាច់បញ្ចូលគ្នានៃនាយកដ្ឋានទឹក និងហ្គាស់ ក្រុងឡុងប៊ិច**

នៅថ្ងៃទី 9 ខែសីហា ឆ្នាំ 2022 ក្រុមប្រឹក្សាក្រុងឡុងប៊ិចបានដាក់វិធានការ BB នៅលើសន្លឹកឆ្នោត។ វិធានការនេះនឹងធ្វើវិសោធនកម្មជាចម្បង នូវមាត្រា XIV និង XV នៃធម្មនុញ្ញទីក្រុងឡុងប៊ិច ដើម្បីឲ្យប្រព័ន្ធទឹកស្អាត, លូ, និងហ្គាស់ នៅក្នុងក្រុងដែលមានស្រាប់ ត្រូវច្របាច់បញ្ចូលគ្នាអោយទៅជានាយកដ្ឋានតែមួយ, ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលទឹកក្រុងឡុងប៊ិច ដែលមានស្រាប់រួចហើយនោះ។ ក្រុមប្រឹក្សាភិបាលនៃគណៈកម្មការទឹកក្រុងឡុងប៊ិចនេះ (Long Beach Board of Water Commissioners) នឹងត្រូវប្តូរឈ្មោះទៅជា ក្រុមប្រឹក្សាភិបាលឧបករណ៍ប្រើប្រាស់ក្រុងឡុងប៊ិច (ទឹក, លូ, និងហ្គាស), ហើយនាយកដ្ឋានទឹកក្រុងឡុងប៊ិច នឹងត្រូវប្តូរឈ្មោះទៅជា នាយកដ្ឋានឧបករណ៍ប្រើប្រាស់ក្រុងឡុងប៊ិច (ទឹក, លូ, និងហ្គាស) វិញ។

វិធានការនេះនឹងផ្ទេរការចាត់ចែង និងការគ្រប់គ្រងឧបករណ៍ប្រើប្រាស់ហ្គាស់ ពីក្រុមប្រឹក្សាក្រុងទៅកាន់ក្រុមប្រឹក្សាភិបាលនៃគណៈកម្មការឧបករណ៍ប្រើប្រាស់សាធារណៈជន, រួមទាំងអំណាចក្នុងការកំណត់តម្លៃ និងការគិតថ្លៃ ដែលទាក់ទងនឹងការផ្តល់ហ្គាស់ធម្មជាតិ។ វិធានការនេះនឹងមិនប៉ះពាល់ដល់តម្រូវការធម្មនុញ្ញដែលមានស្រាប់ ដែលថាការកំណត់តម្លៃ និងការគិតថ្លៃហ្គាស់ជាទូទៅ ត្រូវផ្អែកលើអត្រាទូទៅដែលបានគិតថ្លៃដោយឧបករណ៍ប្រើប្រាស់ហ្គាស់ផ្សេងទៀត នៅក្នុងតំបន់ភាគខាងត្បូងនៃរដ្ឋកាលីហ្វ័រញ៉ា។ វិធានការនេះនឹងមិនធ្វើវិសោធនកម្មនៃការកំណត់បច្ចុប្បន្នលើការផ្ទេរពីមូលនិធិទឹក, លូ, និងហ្គាស់ តែរៀងៗខ្លួន, ទៅកាន់មូលនិធិទូទៅរបស់ទីក្រុងនោះទេ។

នាយកដ្ឋានឧបករណ៍ប្រើប្រាស់ក្រុងផ្សេងៗទៀត អាចត្រូវបានច្របាច់បញ្ចូលគ្នា នាពេលអនាគតនេះ ទៅក្នុងយុត្តាធិការរបស់ក្រុមប្រឹក្សាភិបាលនៃគណៈកម្មការឧបករណ៍ប្រើប្រាស់សាធារណៈដោយសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង។ វិធានការនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិ ឬកាតព្វកិច្ចកិច្ចសន្យាដែលមានស្រាប់របស់នាយកដ្ឋានទឹកក្រុងឡុងប៊ិចនោះទេ។ វិធានការនេះ នឹងមិនប៉ះពាល់ដល់សមាជិកភាពដែលមានស្រាប់ ឬអណត្តិនៃការកាន់តំណែងរបស់គណៈកម្មការបច្ចុប្បន្ននោះទេ។

អ្នកគ្រប់គ្រងទូទៅនាពេលអនាគតនៃនាយកដ្ឋានឧបករណ៍ប្រើប្រាស់សាធារណៈនេះ នឹងត្រូវបានជ្រើសរើសរួមគ្នាដោយក្រុមប្រឹក្សាភិបាលនៃគណៈកម្មការឧបករណ៍ប្រើប្រាស់សាធារណៈ និងអ្នកគ្រប់គ្រងទីក្រុង, ហើយនឹងផ្តល់សេវាតាមការពេញចិត្តរបស់គណៈកម្មការនៅពេលបន្ទាប់នោះ។

ផងដែរ វិធានការនេះក៏នឹងធ្វើការផ្លាស់ប្តូរជាច្រើន ចំពោះមាត្រា III, V, XIV, XV, XVII, XVIII និង XX នៃធម្មនុញ្ញទីក្រុង ដើម្បីឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរឈ្មោះរបស់គណៈកម្មការ, ដើម្បីធ្វើបច្ចុប្បន្នភាពឯកសារយោង ដែលគ្មានបច្ចុប្បន្នភាពឬហួសសម័យ, និងដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែច្បាស់ អំពីការវិវត្តន៍នៃការអនុវត្តល្អបំផុតនៃប្រតិបត្តិការសម្រាប់ឧបករណ៍ប្រើប្រាស់របស់ទីក្រុង។

ប្រសិនបើត្រូវបានអនុម័តដោយអ្នកបោះឆ្នោត វិធានការនេះនឹងចូលជាធរមានភ្លាមៗ, ប៉ុន្តែគេរំពឹងថាដំណើរការជាក់ស្តែងនៃការច្របាច់បញ្ចូលនេះ នឹងចំណាយពេលយ៉ាងហោចណាស់ជាច្រើនខែ ដើម្បីបញ្ចប់វា។

ផលប៉ះពាល់ចំពោះសារពើពន្ធដែលមានសក្តានុពលដែលទាក់ទងនឹងវិធានការនេះមិនច្បាស់លាស់ទេ ប៉ុន្តែគេរំពឹងថាការច្របាច់បញ្ចូលនេះ នឹងបណ្តាលអោយមានការប្រសើរឡើងនូវប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ ហើយជាលទ្ធផល អាចប្រហែលជានឹងកាត់បន្ថយអោយទាបក្នុងការចំណាយនៃកិច្ចប្រតិបត្តិការ ក្នុងរយៈពេលវែង។

ការបោះឆ្នោត "បាទ/ចាស" គឺគាំទ្រដល់ការច្របាច់បញ្ចូលឧបករណ៍ប្រើប្រាស់ទឹក, លូ និងហ្គាស់ក្នុងទីក្រុង អោយក្លាយទៅជានាយកដ្ឋានតែមួយ។

ការបោះឆ្នោត "ទេ" គឺប្រឆាំងនឹងការច្របាច់បញ្ចូលគ្នាឧបករណ៍ប្រើប្រាស់ប្រព័ន្ធទឹក, លូ និងហ្គាស់ក្នុងទីក្រុង អោយក្លាយទៅជានាយកដ្ឋានតែមួយ។

តម្រូវអោយមានសំឡេងភាគច្រើន បោះឆ្នោត "បាទ/ចាស" ដើម្បីឱ្យវិធានការនេះអនុម័ត/ឈ្នះ។

**សេចក្តីថ្លែងការណ៍ខាងលើនេះ គឺជាការវិភាគមិនលំអៀងចំពោះវិធានការ BB។ ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃវិធានការនេះ សូមទូរស័ព្ទទៅកាន់ការិយាល័យស្មៀនក្រុង តាមលេខ 562-570-6101 ហើយច្បាប់ចម្លងនេះ នឹងត្រូវបានផ្ញើទៅអោយអ្នកដោយឥតគិតថ្លៃ។**

CHARLES PARKIN
មេធាវីក្រុងឡុងប៊ិច